# សេចក្តីសន្និដ្ឋានសម្រេចរបស់គណៈកម្មាធិការអនុសញ្ញាស៊ី-ដ ក្នុងការពិនិត្យឡើងវិញមកលើប្រទេសកម្ពុជា

ចាប់ពីថ្ងៃទី២១ ខែតុលា ឆ្នាំ ២០១៩ ដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ប្រទេសកម្ពុជា ត្រូវបានពិនិត្យឡើងវិញដោយគណៈកម្មាធិការស៊ី-ដ ក្នុងសម័យប្រជុំលើកទី ៧៤ របស់ខ្លួនទៅលើការអនុវត្តសិទ្ធិស្ត្រីដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (អនុសញ្ញា ស៊ី-ដ)។



គណៈកម្មាធិការស៊ី-ដ បានផ្តល់នូវអនុសាសន៍មួយចំនួនដូចដែលបានបង្ហាញខាងក្រោម៖

## វិធានការផ្នែកច្បាប់ដើម្បីសមភាព



- ត្រូវធានាថាច្បាប់ក្នុងប្រទេសកម្ពុជាបានដាក់បញ្ចូលនិយមន័យនៃការរើសអើងប្រឆាំងនឹងស្ត្រីភេទដែលគ្របដណ្តប់លើការរើសអើងដោយផ្ទាល់ និងដោយប្រយោលនៅទីកន្លែងសាធារណៈ និងឯកជន។

## ការទទួលបានយុត្តិធម៌ និងដំណោះស្រាយ



- បង្កើតគម្រោងជំនួយផ្នែកច្បាប់ឱ្យបានទូលំទូលាយ និងបង្កើតតុលាការឧទ្ទរណ៍នៅក្នុងតំបន់ដែលមានទីតាំងនៅក្រៅរាជធានីភ្នំពេញ ដើម្បីធានាថាការប្រើប្រាស់ប្រព័ន្ធតុលាការ និងការជំនុំជម្រះក្តីប្រកបដោយប្រសិទ្ធភាពសម្រាប់ស្ត្រីទាំងអស់ ជាពិសេសស្ត្រីជនបទ ស្ត្រីជនជាតិដើមភាគតិច ស្ត្រីដែលនៅក្នុងក្រុមភាគតិច និងស្ត្រីដែលមានពិការភាពជាដើម។
- ពង្រឹងការបញ្ជ្រាបយេនឌ័រនៅក្នុងប្រព័ន្ធយុត្តិធម៌តាមរយៈការបង្កើនចំនួនស្ត្រីនៅក្នុងប្រព័ន្ធតុលាការ និងផ្តល់ការបណ្តុះបណ្តាលសមត្ថភាពដល់សមាជិកទាំងអស់នៅក្នុងប្រព័ន្ធយុត្តិធម៌។

## អ្នកការពារសិទ្ធិមនុស្សជាស្ត្រី



- ធានាឲ្យបានពេញលេញនូវសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី រួមមានថ្នាក់ដឹកនាំសហជីព សកម្មជនដីធ្លី និងបរិស្ថាន និងសមាជិកគណបក្សនយោបាយជំទាស់ ជាពិសេសទៅលើសិទ្ធិសេរីភាពរបស់ពួកគាត់ក្នុងការបញ្ចេញមតិ និងសិទ្ធិក្នុងការជួបប្រជុំ និងសមាគមដោយគ្មានការយាយី ការឃ្លាំមើល ឬការរឹតត្បិតហួសហេតុផ្សេងទៀត។

## អាពាហ៍ពិពាហ៍ និងទំនាក់ទំនងគ្រួសារ



- អនុម័តវិធានការសម្រាប់សហគមន៍ដែលមានអត្រារៀបការខ្ពស់របស់កុមារ មានដូចជាសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍ជនបទ រួមបញ្ចូលកម្មវិធីលើកកម្ពស់ការយល់ដឹងស្តីពីផលប៉ះពាល់ដែលបង្កគ្រោះថ្នាក់ដោយសារការរៀបអាពាហ៍ពិពាហ៍នៅវ័យកុមារ ហើយការរៀបអាពាហ៍ពិពាហ៍នៅក្រោមអាយុ ១៨ឆ្នាំ ត្រូវតែហាមឃាត់ជាដាច់ខាត។ មាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណីដែលហាមឃាត់ស្ត្រីក្នុងការរៀបការម្តងទៀតក្នុងអំឡុងពេល ១២០ថ្ងៃ ក្រោយការលែងលះ។
- អនុម័តយុទ្ធសាស្ត្រឱ្យបានស៊ីជម្រៅជាមួយនឹងវិធានការត្រៀមទុកជាមុនឱ្យបានសកម្ម និងប្រកបដោយនិរន្តរភាពដើម្បីលុបបំបាត់ឥរិយាបថរើសអើង និងផ្នត់គំនិតចាស់គំរិលទាក់ទងទៅនឹងតួនាទី និងទំនួលខុសត្រូវរបស់ស្ត្រី និងបុរសនៅក្នុងគ្រួសារ និងសង្គម។

## ការចូលរួមក្នុងកិច្ចការសាធារណៈ និងនយោបាយ



- ធានាឱ្យបានពេញលេញនូវសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី រួមមានថ្នាក់ដឹកនាំសហជីព សកម្មជនដីធ្លី និងបរិស្ថាន និងសមាជិកគណបក្សនយោបាយជំទាស់ ជាពិសេសទៅលើសិទ្ធិសេរីភាពរបស់ពួកគាត់ក្នុងការបញ្ចេញមតិ និងសិទ្ធិក្នុងការជួបប្រជុំ និងសមាគមដោយគ្មានការយាយី ការឃ្លាំមើល ឬការរឹតត្បិតហួសហេតុផ្សេងទៀត។

ឧបត្ថម្ភដោយ ផលិតដោយ

EUROPEAN UNION DCA actalliance VOICES for GENDER EQUALITY មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights

@CCHRCambodia @CCHRCambodia @EU.Cambodia

BY NC SA

ខែមិថុនា ឆ្នាំ២០២០